ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ...៤៩៩៩......អពដ

រាជធានីភ្នំពេញ ថ្ងៃទី២៣ខែ មីនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឲ្យដំណើរការ ការបង់ប្រាក់ពន្ធ-អាករគ្រប់ប្រភេទ នៅធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី

ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈឱ្យកាន់តែមានគុណភាព ស័ក្តិសិទ្ធិ គួរឱ្យទុកចិត្ត ឆាប់រហ័ស ងាយស្រួល សមស្របទៅនឹងសេចក្តីត្រូវការរបស់អ្នកជាប់ពន្ធ កន្លងមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ស្តីពីការប្រើប្រាស់សេវាកម្មរបស់ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី សម្រាប់ប្រតិបត្តិការប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទ អនុវត្តនៅទូទាំងប្រទេស។

ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារ សូមជម្រាបជូនឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ម្ចាស់សហគ្រាស អ្នកជាប់ពន្ធទាំងអស់មេត្តាជ្រាបថា ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី បានត្រៀមលក្ខណៈរួចរាល់ និង**ដាក់ឱ្យដំណើរការទទួលប្រាក់ពន្ធ-អាករគ្រប់ប្រភេទ ចាប់ពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ តទៅ**។ ដូច្នេះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ម្ចាស់សហគ្រាស អ្នកជាប់ពន្ធ អាចអញ្ជើញទៅបង់ប្រាក់ពន្ធ-អាករគ្រប់ប្រភេទ នៅតាមបញ្ជរបង់ប្រាក់ពន្ធ (Counter) របស់ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី នៅការិយាល័យកណ្តាល និងតាមបណ្តាសាខាទូទាំងព្រះរាជាណាចក្រកម្ពុជា តាមពេលវេលាបម្រើសេវាកម្ម ដូចខាងក្រោម÷

- ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ
- ម៉ោង ០៨ : ០០ ព្រឹក រហូតដល់ម៉ោង ១៦ : ០០ ល្ងាច

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ម្ចាស់សហគ្រាស អ្នកជាប់ពន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងអាចអញ្ជើញទៅបង់ប្រាក់ពន្ធនៅតាមទីកន្លែងនិងពេលវេលាដូចជម្រាបជូនខាងលើ ក្នុងករណីឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា ឧកញ៉ា លោក-លោកស្រី មានបំណងប្រើប្រាស់សេវាបង់ប្រាក់ពន្ធរបស់ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី។

អគ្គនាយកដ្ឋានពន្ធដារ

ទំនាក់ទំនង ÷

- អគ្គនាយកដ្ឋានពន្ធដារ ÷
  លោក **ហ៊ិល ធីរិត** ទូរស័ព្ទលេខ ០១២ ៤៣៥ ១៥២
- ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី ÷
  លោក **សុខ ស៊ីកៅ** ទូរស័ព្ទលេខ ០១២ ៩១៥ ១៤៨

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh